# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិ ប្រយុទ្ធនឹងជំងឺអេដស៍
នាយកដ្ឋានផែនការ ត្រួតពិនិត្យ វាយតម្លៃ និងស្រាវជ្រាវ

## កំណត់ហេតុ
## កិច្ចប្រជុំការងារបច្ចេកទេសប្រចាំសប្តាហ៍

**ថ្ងៃ ច័ន្ទ ទី ០៨ ខែ មិថុនា ឆ្នាំ ២០១៥ នៅសាលប្រជុំ អ.ជ.ប.ជ.អ**

នៅវេលាម៉ោង ៩:០០ នាទីព្រឹក ថ្ងៃច័ន្ទ ទី០៨ ខែ មិថុនា ឆ្នាំ២០១៥ អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ មានរៀបចំកិច្ចប្រជុំការងារបច្ចេកទេសប្រចាំសប្តាហ៍ របស់ខ្លួនក្រោមការដឹកនាំកិច្ចប្រជុំដោយឯកឧត្តមវេជ្ជបណ្ឌិត តែង គន្ធី អគ្គលេខាធិការ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដោយមានការចូលរួមពីអគ្គលេខាធិការរង ប្រធាន និងអនុប្រធាននាយកដ្ឋានក្រោមឱវាទអគ្គលេខាធិការដ្ឋាន។

**១. សមាសភាពចូលរួម:**

សមាសភាពចូលរួមក្នុងកិច្ចប្រជុំថ្ងៃនេះ មានអគ្គលេខាធិការ អគ្គលេខាធិការរង ប្រធាននាយកដ្ឋាន អនុប្រធាននាយកដ្ឋាន សរុបទាំងអស់ចំនួន ១៧ រូប (មានភ្ជាប់ជូនបញ្ជីវត្តមានចូលរួម)។

**២. អវត្តមាន** ( ៤ រូប )

១ ឯកឧត្តម អាំង សំបូរ ( ច្បាប់ )
២ ឯកឧត្តម. ឈឹម ឃិនដារ៉េត ( ច្បាប់ )
៣ លោកវេជ្ជ. វ៉ឹង យ៉ាណាត ( ច្បាប់ )
៤ លោកស្រីវេជ្ជ. ស៊ូ សុភី ( ច្បាប់ )

**៣. ប្រធានបទនៃកិច្ចប្រជុំ**

- របាយការណ៍សកម្មភាពសំរាប់សប្តាហ៍កន្លងមកនិងសកម្មភាពសំរាប់សប្តាហ៍បន្ទាប់របស់នាយកដ្ឋាននីមួយៗ
- សំណូមពររួម និងផ្សេងៗ

- ការណែនាំរបស់អគ្គលេខាធិការតាមនាយកដ្ឋាន

**៤. ដំណើរការ និងលទ្ធផលនៃកិច្ចប្រជុំ**

ជាកិច្ចចាប់ផ្តើមនៃអង្គប្រជុំ ឯកឧត្តមវេជ្ជ. តែង គន្ធី អគ្គលេខាធិការ អាជ្ញាធរជាតិយុទ្ធនឹងជំងឺអេដស៍មានមតិស្វាគមន៍ចំពោះ ឯកឧត្តម លោក លោកស្រី អគ្គលេខាធិការរង ប្រធាន និងអនុប្រធាននាយកដ្ឋានទាំងអស់ ដែលបានចូលរួមក្នុងកិច្ចប្រជុំនាព្រឹកនេះ ។ ជាកិច្ចបន្ត ឯកឧត្តមប្រធានអង្គប្រជុំបានរំលឹកដល់នាយកដ្ឋាន PMER ពី:

- របាយការណ៍សិក្ខាសាលាស្តីពីផែនការយុទ្ធសាស្រ្តជាតិទី៤ (Descriptivereport) មុនរបាយការណ៍បច្ចេក ទេសក្រោយ។
- ចំពោះរបាយការណ៍បេសកកម្មគោលបំណងយើងចង់បានតួរលេខអ្នកប្រឈមមុខខ្ពស់ ( MSM, EW...) ដើម្បីរៀបចំធ្វើ Mapping ( សូមបញ្ចូលរបាយការណ៍ទៅកំពតនិងរតនៈគីរីផង )។
- របាយការណ៍៦ខែដើមឆ្នាំសម្រាប់ផ្សព្វផ្សាយពេលប្រជុំ PAB ថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០១៥ នេះ។
- ឯកឧត្តមនឹងពិភាក្សាជាមួយឯកឧត្តម ទា ផលា លើការបកប្រែផែនការយុទ្ធសាស្រ្តជាតិទី៤ ឲ្យទាន់ថ្ងៃប្រជុំ នោះដែរ ដើម្បីធ្វើចេញទៅគ្រប់ PAB និង PAS និងក្រសួងសមាជិកឲ្យបានមុនថ្ងៃប្រជុំ(គឺនៅថ្ងៃទី ១៩ ខែមិថុនា ឆ្នាំ ២០១៥ )។

**៤.១.នាយកដ្ឋានផែនការ ត្រួតពិនិត្យ វាយតំលៃ និងស្រាវជ្រាវ**

លោកវេជ្ជ. រស់ សីលវ៉ាត់ បានរាយការណ៍ ជូនអង្គប្រជុំទាក់ទងនឹងការងារដែលបានអនុវត្តក្នុងសប្តាហ៍កន្លងមក និងសកម្មភាពសម្រាប់អនុវត្តក្នុងសប្តាហ៍បន្ទាប់រួមមានៈ

- រៀបចំសិក្ខាសាលា validation on NSP IV ហើយយើងនឹងពិនិត្យបញ្ចូលជាពង្រាងចុងក្រោយនាសប្តាហ៍នេះ។
- រៀបចំផែនការសកម្មភាពលំអិតក្នុងគំរោងមូលនិធិសាកលសំរាប់អាជ្ញាធរជាតិប្រយុទ្ធនិងជម្ងឺអេដស៍ឆ្នាំ២០១៥ ដល់ ២០១៧ និងបញ្ជូននៅក្នុងសប្តាហ៍នេះ ។
- បញ្ជូនតួរលេខទាក់ទងផែនការវិនិយោគ ៣ឆ្នាំរំកិលរបស់វិស័យអេដស៍ ទៅក្រសួងផែនការ។
- បញ្ចប់និងរៀបចំបញ្ជូនរបាយការណ៍អធិប្បាយទៅ UNAIDS។
- ចាត់មន្ត្រីចុះបេសកកម្មនៅខេត្តកំពង់ស្ពឺ។
- បញ្ចប់របាយការណ៍ GARPR តែរង់ចាំការពិនិត្យកែលំអរចុងក្រោយពី ឯកឧត្តម ទា ផលា ហើយនិង ដាក់ជូន ឯកឧត្តមប្រធានចុះហត្ថលេខា មុននឹងអាចបញ្ជូនចេញ ដែលការពិតត្រូវធ្វើអោយបានមុន ថ្ងៃទី៧ មិថុនា ២០១៥ ។ ចំនុចដែលត្រូវពិនិត្យកែលំអរគឺ ១) ការត្រូវអធិប្បាយ

ពីគោលដៅ ៣សូន្យ (ដែលមិនសូវច្បាស់លាស់) រឺយុទ្ធសាស្ត្រ ៩០/៩០/៩០ (ដែលជាក់លាក់ជាង) និង ២) ការសង្កេត ឃើញរបាយការណ៍ថ្មីៗស្តីពីការខ្វះថ្នាំនិងអ្នកជំងឺបោះបង់ការព្យាបាល (loss to follow-up)។

ទាក់ទងនឹងចំនុចអ្នកជំងឺបោះបង់ការព្យាបាល(loss to follow-up) ឯកឧត្តមវេជ្ជ. ហោ ប៊ុនឡេង បានស្នើថាយើងជាអាជ្ញាធរគួរពិនិត្យតែលើទិន្នន័យ ប្រមូលបានពីស្ថាប័នរដ្ឋដែលជាបណ្តាញរបស់យើងមិនគួរពិចារណាការយល់ឃើញដោយអត្តនោម័ត ពីអង្គការសង្គមស៊ីវិលណាមួយទេ។ ពេលខ្លះការប្រមូលព័ត៌មានរបស់ អ្នកអនុវត្តការងារអាចមានកំហុសឆ្គង ដូចជាអ្នកជំងឺជាទំលាប់មិនសូវត្រលប់មកវិញចំថ្ងៃណាត់ជួបរបស់គ្រូពេទ្យទេ ប៉ុន្តែគាត់នៅតែមកជួបជាមួយគ្រូពេទ្យដដែលទោះខុសថ្ងៃណាត់។ នេះមិនមែនជាការបោះបង់ការព្យាបាលទេគ្រាន់តែខុសថ្ងៃ តែការបកអធិប្បាយអាចមាន ន័យដូចជាការបោះបង់ការព្យាបាល។ នេះជាចំណុចដែលយើងត្រូវពិចារណា។

ចំពោះ ៩០/៩០/៩០ វាជាយុទ្ធសាស្ត្រ ជ្រកក្រោមគោលនយោបាយ បី សូន្យ របស់ UNAIDS ដែលយើងជាសមាជិកអង្គការសហប្រជាជាតិយើងអាចយកមកប្រើក៏បាន មិនយកក៏បាន។ ការពិតទៅ UNAIDS ត្រូវមាននាទីផ្សព្វផ្សាយជំរុញអោយរដ្ឋសមាជិកយកទៅអនុវត្ត តែគេមិនដែលនិយាយជាមួយអាជ្ញាធរយើង។ កាលពីថ្ងៃមុនមានការប្រជុំមួយនៅប្រទេសថៃនិយាយពី៩០/៩០/៩០ ក្នុងនោះមាន NCHADS ចូលរួម តែមិនមានអាជ្ញាធរអេដស៍។

លោកវេជ្ជ. ទេព ណារុធ បានរាយការណ៍ពីការប្រជុំ CAM Info ដោយឲ្យអាជ្ញាធរយើងផ្ញើទិន្ន័យថ្មីចុង ក្រោយដែលមានទាក់ទងនិងការអភិវឌ្ឍន៍ជាតិ NSDP នៅក្នុងមិថុនានេះ។ មួយទៀត យើងត្រូវ install CAM Info ប្រើប្រាស់បាន ហើយក្រសួងផែនការអាចមកជួយ install ។

### ៤.២. នាយកដ្ឋាន បង្ការ ថែទាំ និង គាំទ្រ

លោកវេជ្ជ. អ៊ឹង សុវណ្ណៈ បានរាយការណ៍ ជូនអង្គប្រជុំទាក់ទងនឹងការងារដែលបាន អនុវត្តក្នុង សប្តាហ៍កន្លងមក និងសកម្មភាពសំរាប់អនុវត្តក្នុងសប្តាហ៍បន្ទាប់ ដែលក្នុងនោះរួមមានដូចខាងក្រោមៈ

- បានរៀបចំផែនការថវិកា ឆ្នាំ២០១៧
- បានចាត់មន្ត្រីចុះបេសកកម្ម ខេត្ត បាត់ដំបង និង កំពង់ស្ពឺ
- បានរៀបចំផែនការ OVC នៅក្រសួងសង្គមកិច្ចការងារ
- រៀបចំកិច្ចប្រជុំលេខាធិការដ្ឋានក្រុមការងារបុរសស្រលាញ់បុរស និងត្រៀមរៀបចំកិច្ចប្រជុំក្រុមការងារ និងវគ្គហ្វឹកហ្វឺន

### ៤.៣. នាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ

ឯ.ឧ ស៊ិន ពិសិដ្ឋ បានរាយការណ៍ ជូនអង្គប្រជុំទាក់ទងនឹងការងារដែលបានអនុវត្ត ក្នុងសប្តាហ៍កន្លងមក និងសកម្មភាពសំរាប់អនុវត្តក្នុងសប្តាហ៍បន្ទាប់ ដែលក្នុងនោះរួមមានដូចខាងក្រោម៖

- បានរៀបចំឯកសារឡើងទូទាត់ជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានរៀបចំឯកសារចំណាយសម្រាប់បេសកកម្ម
- រៀបចំទូទាត់ការប្រជុំគណៈកម្មការអេដស៍ខេត្តកំពត និងរតនៈគីរី រួចរាល់
- ពិនិត្យថវិកាសម្រាប់ប្រជុំគណៈកម្មការអេដស៍ខេត្ត អាចធ្វើបានក្រោម២ ០០០ ០០០៛ និងធ្វើលិខិតជូនដំណឹងទៅតាមខេត្តក្នុងសប្តាហ៍នេះ ។

បានធ្វើលិខិតស្នើសុំបន្ទប់ប្រជុំទៅទីស្តីការគណៈរដ្ឋមន្ត្រី សម្រាប់ការប្រជុំក្រុមប្រឹក្សាគោលនយោបាយ ថ្ងៃទី ២៦ ខែមិថុនា ២០១៥ រួចហើយ។ ទាក់ទងនឹងកិច្ចប្រជុំនេះ គោលការណ៍ពីក្រសួងហិរញ្ញវត្ថុ នៅមិនទាន់ចេញនៅឡើយ។ ដោយមានការលំបាកខាងបច្ចេកទេស ព្រោះការងារចំបងមួយដែលត្រូវយកទៅពិនិត្យទាក់ទងនឹង ឯកសារផែនការយុទ្ធសាស្ត្រជាតិទី៤ ដែលនៅមិនទាន់បញ្ចប់ ហើយការបកប្រែជា ភាសាជាតិអាចធ្វើមិនទាន់ ឯកឧត្តម ហោ ប៊ុនឡេងនិងអង្គប្រជុំស្នើរពិចារណាពន្យារពេល។ តែយោងតាមការបែបបទហិរញ្ញវត្ថុ ការលើកពេលអាចមានការលំបាកក្នុងការទូទាត់។ ឯកឧត្តម ស៊ិន ពិសិដ្ឋ បានផ្តល់យោបល់ថាយើងអាចសុំលើកបានបន្ទាប់ពីចេញគោលការណ៍ហើយ យើងត្រូវធ្វើលិខិតសុំដូរថ្ងៃប្រជុំមួយ ។ ឯ.ឧ. អគ្គលេខាធិការនឹងពិនិត្យការងារនេះជាមួយថ្នាក់ដឹកនាំ។ ពាក់ព័ន្ធនិងបន្ទប់ប្រជុំ ឯកឧត្តមអគ្គលេខាបានផ្តល់យោបល់ថា ដោយជំរើសបន្ទប់មានតែ ២ គឺ A រឺ B យើងអាចដាក់ឈ្មោះបន្ទប់ប្រជុំណាមួយដែល ប្រហែលមានលទ្ធភាពខ្ពស់ជាងគេតែម្តង ហើយជាក់ស្តែងបើបានការអនុញ្ញាតិខុសពីនោះ សឹមយើងជូនដំណឹង ទៅថ្នាក់ដឹកនាំដែលនឹងចូលរួមជាក្រោយហើយដាក់អ្នកចាំនាំផ្លូវ។

### ៤.៤. នាយកដ្ឋាន CRM៖ មិនមានរបាយការណ៍

## ៥. សកម្មភាពក្នុងសប្តាហ៍បន្ទាប់:

### ៥.១. នាយកដ្ឋាន ផែនការ ត្រួតពិនិត្យ វាយតម្លៃ និងស្រាវជ្រាវ៖

- រៀបចំកិច្ចប្រជុំនាយកដ្ឋានព្រឹកថ្ងៃទី ៩ មិថុនា ២០១៥
- បញ្ចប់របាយការណ៍ GARPR និងស្នើរសុំការអនុមតិជាផ្លូវការពីឯ.ឧ. ទេសរដ្ឋមន្ត្រីប្រធាន ហើយបញ្ជូនទៅអង្គការសហប្រជាជាតិទទួលបន្ទុកការងារអេដស៍
- រៀបចំរបាយការណ៍សិក្ខាសាលាថ្ងៃទី ២ ឧសភា ២០១៥

- បញ្ចប់ផែនការយុទ្ធសាស្ត្រជាតិលើកទី ៤
- រៀបចំការរក្សាទិន្នន័យបច្ចុប្បន្នភាពស្ថានភាពរាលដាលនិងការឆ្លើយតប បានពីការប្រមូល តាមការចុះតាមដាន
- បន្តប្រមូលទិន្នន័យពីស្ថាប័នពាក់ព័ន្ធ ដើម្បីបង្កើតរបាយការណ៍ឆមាសទី១ ត្រៀមសំរាប់កិច្ចប្រជុំក្រុមប្រឹក្សាគោលនយោបាយ
- ពិភាក្សាបន្ថែមការងារ CAM-Info។

### ៥.២. នាយកដ្ឋាន បង្ការ ថែទាំ និង គាំទ្រ

- រៀបចំការប្រជុំលេខាធិការដ្ឋានក្រុមបុរស ស្រឡាញ់បុរស ថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០១៥
- រៀបចំប្រជុំក្រុមការងារក្រុមបុរស ស្រឡាញ់បុរស នៅថ្ងៃទី ១៧ មិថុនា ២០១៥ នៅសៀមរាប
- ចុះបង្រៀនដល់ក្រុមប្រឹក្សាឃុំ សង្កាត់នៅសាលាខេត្តសៀមរាបថ្ងៃទី ២២ ដល់២៤ ខែ មិថុនា ឆ្នាំ ២០១៥ ទាក់ទងការងារក្មេងកំព្រា

## ៦. សំណូមពររួម និងផ្សេងៗ

លោកវេជ្ជ. ស៊ឹម គឹមសាន សុំឲ្យលោកប្រធានរដ្ឋបាល និងហិរញ្ញវត្ថុ ពិនិត្យ និងជំរុញលើថវិកាប្រជុំតាមខេត្តដើម្បីឲ្យខេត្តបានរៀបចំការប្រជុំ ព្រោះឆ្នាំកន្លងមកខែបី បានប្រជុំខ្លះហើយ និងជំរុញឲ្យការទូទាត់បេសកកម្មឲ្យបានឆាប់ដើម្បីបានថវិកាចុះខែបន្ទាប់។

## ៧. ភារៈកិច្ចបន្តសំរាប់សប្តាហ៍បន្ទាប់ៈ

- លោកវេជ្ជ. ទេព ណារុធ ធ្វើលិខិតជាផ្លូវការមួយដើម្បីឯកឧត្តមអគ្គលេខាធិការ ស្នើសុំទៅ ឯកឧត្តមប្រធានបង្កើតជាក្រុមមួយសម្រាប់រៀបចំការងារនេះដោយមាន លោកវេជ្ជ. ទេព ណារុធ ទំនាក់ទំនងជាមួយលោកវេជ្ជ. រស់ សីលវ៉ាត់ ។
- លោកវេជ្ជ. អ៊ុក ម៉ារឌី ត្រូវមានលិខិតអញ្ជើញពីក្រសួងសង្គមកិច្ចការងារ ដាក់ជូន ឯកឧត្តមប្រធាន
- ពេលយកលិខិតទៅជូនឯកឧត្តមសុំឲ្យមានលិខិតបញ្ជាក់សុំអនុញ្ញាតចូលរួមដោយសារ........
- លោកវេជ្ជ. ស៊ឹម គឹមសានធ្វើរបាយការណ៍ចុះទៅរតនៈគីរី និងរៀបចំការប្រជុំថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០១៥ដោយធ្វើបញ្ជីឈ្មោះអ្នកចូលរួមទាំងអស់ឲ្យទៅរដ្ឋបាលនៅថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១៥ នៅថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០១៥ ឯកឧត្តមពិនិត្យឡើងវិញ ។
- រៀបក្រុមចុះបេសកកម្ម ២ខេត្តសម្រាប់ខែក្រោយៈ

១. ឯឧ. ជា ប៉ោ ខេត្តសៀមរាប

២. ឯឧ. ហោ ប៊ុនឡេង ខេត្តបន្ទាយមានជ័យ

៣. លោកវេជ្ជ. ស៊ឹម គឹមសាន ខេត្តរតនៈគីរី

- នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ចូលរួមប្រជុំជាមួយឯកឧត្តមអគ្គលេខាធិការនៅថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១៥ ម៉ោង ០៩ ព្រឹក ។(វត្តមានចំបាច់)
- លោក ស៊ន ពិសិដ្ឋ ពិនិត្យ និងជំរុញការទូទាត់បេសកកម្មឲ្យបានទាន់ពេលវេលា និងថវិកាសម្រាប់ការប្រជុំតាមខេត្ត។
- ក្នុងកំឡុងពេល៣ថ្ងៃបន្ទាប់ពីបញ្ចប់បេសកកម្មត្រូវធ្វើរបាយការណ៍ឲ្យហើយ ។
- របាយការណ៍បេសកកម្មត្រូវមាន ថតចម្លងបេសកកម្ម របាយការណ៍បច្ចេកទេស និងរបាយការណ៍បញ្ជីសំណួរមានអនុហត្ថលេខា របស់ឯកឧត្តមអគ្គលេខាធិការ។

កិច្ចប្រជុំបានបញ្ចប់នៅវេលាម៉ោង ១០:១០ នាទីព្រឹក ថ្ងៃ ខែ ឆ្នាំ ដដែល ប្រកបដោយបរិយាកាសរីករាយ និងស្និទ្ធស្នាល ជាទីបំផុត។

ថ្ងៃទី ៩ ខែ មិថុនា ឆ្នាំ២០១៥

| | | |
|---|---|---|
| | ឯកភាពនិងគោរពជូនឯ.ឧ.អគ្គលេខា<br>ពិនិត្យសំរេច | មន្ត្រីទទួលបន្ទុក |
| បានឃើញ និងឯកភាព<br>អគ្គលេខាធិការ | អគ្គលេខាធិការរងនិង<br>ជាប្រធាននាយកដ្ឋាន | **ឱសថ. ចេង ថា** |
| | **វេជ្ជ. រស់ ស៊ីលវ៉ាត់** | |
| **ឯកឧត្តមវេជ្ជ. តែង គន្ធី** | | |